ផ្សារមូលបត្រកម្ពុជា
CSX
ក្រុមហ៊ុន ផ្សារមូលបត្រកម្ពុជា
លេខ: ......១០៥/១៧...

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

*ថ្ងៃសុក្រ ១២កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១*
*រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៧*

## សេចក្តីជូនដំណឹង
## ស្តីពីការដាក់ឱ្យដំណើរការ វិធីសាស្ត្រជួញដូរតាមការចរចា, បញ្ជាទីផ្សារ, និងដែនកំណត់ថ្លៃប្រចាំថ្ងៃ១០% សម្រាប់ទីផ្សារមូលបត្រកម្មសិទ្ធិ

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សមាជិក វិនិយោគិន និងសាធារណជនទាំងអស់មេត្តាជ្រាបថា ផ.ម.ក. នឹងដាក់ឱ្យដំណើរការ **វិធីសាស្ត្រជួញដូរតាមការចរចា** (Negotiated Trading Method), **បញ្ជាទីផ្សារ** (Market Order), **និងដែនកំណត់ថ្លៃប្រចាំថ្ងៃ១០%** សម្រាប់ការជួញដូរមូលបត្រកម្មសិទ្ធិនៅ ផ.ម.ក. ចាប់ពីថ្ងៃអង្គារ ៨រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ដែលត្រូវនឹងថ្ងៃទី ៩ ខែ មករា ឆ្នាំ២០១៨ ខាងមុខនេះតទៅ ដោយយោងតាមប្រកាសរបស់គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក) លេខ ០១៧/១៧ គ.ម.ក./ប្រ.ក. ចុះថ្ងៃអង្គារ ៩កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ដែលត្រូវនឹងថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

**វិធីសាស្ត្រជួញដូរតាមការចរចា** គឺជាវិធីសាស្ត្រជួញដូរថ្មីបន្ថែមពីលើវិធីសាស្ត្រជួញដូរបច្ចុប្បន្នដែលផ្អែកលើការដេញថ្លៃ។ វិធីសាស្ត្រថ្មីនេះ នឹងអនុញ្ញាតឱ្យវិនិយោគិនធំមួយគូដែលបានចរចារគ្នាលើលក្ខខណ្ឌនៃការជួញដូររួចហើយ អាចដាក់បញ្ជាទិញនិងលក់ជាសម្ងាត់មក ផ.ម.ក. ដើម្បីធ្វើការជួញដូរជាផ្លូវការ។

**បញ្ជាទីផ្សារ** គឺជាប្រភេទបញ្ជាថ្មីបន្ថែមពីលើបញ្ជាបច្ចុប្បន្នដែលមានឈ្មោះថា "បញ្ជាដែនកំណត់" (Limit Order)។ ប្រភេទបញ្ជាថ្មីនេះ ឆ្លើយតបទៅនឹងតម្រូវការរបស់វិនិយោគិន ដែលមានបំណងចង់ទិញឬលក់មូលបត្រឱ្យបានភ្លាមៗតាមតម្លៃទីផ្សារ។

**ដែនកំណត់ថ្លៃប្រចាំថ្ងៃ១០%** (បង្កើនពី៥%) នឹងទាក់ទាញឱ្យមានចំណេញមូលធន(capital gain)ច្រើនជាងមុន និងអនុញ្ញាតឱ្យវិនិយោគិនមានសេរីភាពច្រើនជាងមុនក្នុងការកំណត់ថ្លៃជួញដូរភាគហ៊ុន បន្ទាប់ពីវិនិយោគិនសាធារណៈមានបទពិសោធន៍និងចំណេះដឹងទាក់ទងនឹងការជួញដូរភាគហ៊ុនជិត៦ឆ្នាំ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមក ផ.ម.ក. តាមរយៈទូរសព្ទ លេខ (+៨៥៥) ២៣ ៩៥ ៨៨៨៨ ឬអ៊ីម៉ែល market@csx.com.kh។

**ផ្សារមូលបត្រកម្ពុជា**